# ប្រទេសកម្ពុជា: អភិវឌ្ឍន៍សេដ្ឋកិច្ចនាពេលថ្មីៗ និង ទស្សនវិស័យ

ស្នាដៃសេដ្ឋកិច្ចដ៏រឹងមាំរបស់ប្រទេសកម្ពុជាបានបន្តនៅក្នុងឆ្នាំ ២០០៦ ជាមួយនឹងកំណើនផលិតផលក្នុងស្រុកសរុប (GDP) ប៉ាន់ស្មានប្រហែល ១០,៥ ភាគរយ ដែលបង្ហាញនូវកំណើនលេខពីរខ្ទង់ក្នុងរយៈពេលបីឆ្នាំជាប់ៗគ្នា។ កំណើននៅបន្តទ្រទ្រង់ដោយការនាំចេញសម្លៀកបំពាក់ វិស័យទេសចរណ៍ សំណង់ និង ការពង្រីកវិស័យកសិកម្ម។ វិស័យកាត់ដេរដែលផ្តល់ការងារជូនដល់ ១០ ភាគរយនៃកម្លាំងពលកម្ម និង មានចំនួន ១៤ ភាគរយនៃ GDP ក្នុងឆ្នាំ ២០០៦ បានពង្រីកបន្ថែមទៀត ជាមួយនឹងការនាំចេញដែលកើនឡើង ២០ ភាគរយ នៅក្នុងឆ្នាំ ២០០៦។ ទន្ទឹមនឹងនេះ កំណើន ២០ ភាគរយនៃការមកដល់របស់ភ្ញៀវទេសចរ បាននាំឱ្យមានកំណើន ២៦ ភាគរយនៅក្នុងចំណូលពីវិស័យទេសចរ។ វិស័យកសិកម្មបានបន្តពង្រីក (៤,៤ ភាគរយ) ខណៈដែលវិស័យសំណង់បានបន្ថយល្បឿនបន្តិច។

ស្ថានភាពអន្តរជាតិ និងក្នុងស្រុកមានលក្ខណៈអំណោយផលល្អសម្រាប់ទស្សនវិស័យសេដ្ឋកិច្ចដ៏ល្អជាបន្តនៅក្នុងឆ្នាំ ២០០៧។ សសរទ្រូងកំណើនទាំងបួន ពោលគឺ វិស័យកាត់ដេរ ទេសចរណ៍ សំណង់ និង កសិកម្ម ត្រូវបានរំពឹងថានឹងបន្តរីកលូតលាស់នៅក្នុងឆ្នាំ ២០០៧ ជាមួយនឹងកំណើន GDP ពិតប៉ាន់ស្មានប្រហែល ៩,០ ភាគរយ។ កំណើនទូទៅក៏ត្រូវបានរំពឹងផងដែរថានឹងបន្តនៅរឹងមាំនៅក្នុងរយៈពេលមធ្យម។ កំណើនវិនិយោគបរទេសផ្ទាល់ (FDI) ត្រូវបានរំពឹងថានឹងនៅបន្តលូតលាស់ ហើយការរកឃើញប្រេងកាតនិងឧស្ម័នក្នុងសមុទ្រ ទំនងជានឹងនាំឱ្យមានកំណើនកាន់តែខ្ពស់ (ផលិតកម្មត្រូវបានរំពឹងថានឹងចាប់ផ្តើមនៅក្នុងឆ្នាំ ២០០៩ ឬ ២០១០)។ ប៉ុន្តែ បច្ចុប្បន្ននេះ វិស័យកាត់ដេរកំពុងប្រឈមមុខនឹងការប្រកួតប្រជែងកាន់តែខ្លាំងឡើងពីការចូលក្នុងអង្គការពាណិជ្ជកម្មពិភពលោក (WTO) របស់ប្រទេសវៀតណាម និង លទ្ធភាពនៃការប្រកួតប្រជែងកាន់តែច្រើនឡើងពីប្រទេសចិននៅក្នុងឆ្នាំ ២០០៨។ ទន្ទឹមនឹងនេះ កំណើនវិស័យកសិកម្មនៃប្រទេសកម្ពុជាមានលក្ខណៈប្រែប្រួលច្រើននៅក្នុងរយៈពេលពីរបីឆ្នាំចុងក្រោយនេះ ដែលជាហេតុធ្វើឱ្យវិស័យនេះមានលក្ខណៈមិនអាចព្យាករណ៍បាន។ វិស័យប្រេងកាតក៏នឹងនាំមកនូវបញ្ហាប្រឈមបន្ថែមទៀតផងដែរចំពោះម៉ាក្រូសេដ្ឋកិច្ច និង ការគ្រប់គ្រងសារពើពន្ធ។ ហេតុនេះ ស្នាដៃម៉ាក្រូសេដ្ឋកិច្ចរឹងមាំ ដែលទ្រទ្រង់ដោយគោលនយោបាយសារពើពន្ធនិងរូបិយវត្ថុដ៏ប្រយ័ត្នប្រយែង ត្រូវបានរំពឹងថានឹងបន្តទៅទៀត ទោះបីជាកាលានុវត្តភាពនិងហានិភ័យថ្មីៗទាំងនេះក៏នឹងកំណត់ផងដែរនូវទស្សនវិស័យរយៈពេលមធ្យមក្តី។

ស្ថានភាពអន្តរជាតិក៏មានលក្ខណៈវិជ្ជមានផងដែរក្នុងឆ្នាំ ២០០៦។ ទោះបីជាមានសម្ពាធពីតម្លៃប្រេងកាតពិភពលោកដ៏ខ្ពស់ក្តី ក៏ជញ្ជីងទូទាត់បានប្រសើរឡើង ខណៈដែលឱនភាពគណនីចរន្ត (លើកលែងការ

ផ្ទេរ) បានថយចុះដល់ -៧,៧ ភាគរយក្នុងឆ្នាំ ២០០៦ (ពី-៩,៦ ភាគរយក្នុងឆ្នាំ ២០០៥) ហើយរូបិយវត្ថុបម្រុងអន្តរជាតិសរុបបានកើនឡើង ២០ ភាគរយ ដល់ US$១,១ ពាន់លាន។ វិនិយោគបរទេសផ្ទាល់បានបន្តនិន្នាការរីកចំរើនដែលឡើងដល់កំរិតឯកទគ្គកម្មខ្ពស់ US$៤៧៥ លាន។ អតិផរណាតម្លៃទំនិញប្រើប្រាស់បានថយចុះមក ២,៨ ភាគរយ (ពី ៦,៧ ភាគរយក្នុងឆ្នាំ ២០០៥) ដោយសារការធ្លាក់ចុះនៃសម្ពាធថ្លៃប្រេង និង ការថយចុះយ៉ាងច្រើននៃសន្ទស្សន៍តម្លៃស្បៀងអាហារ និងសម្លៀកបំពាក់។ សន្ទស្សន៍តម្លៃទំនិញប្រើប្រាស់ត្រូវបានរំពឹងថានឹងស្ថិតនៅទាប (ក្រោម ៥ ភាគរយ) សម្រាប់ឆ្នាំ ២០០៧ ហើយប្រាក់រៀលត្រូវបានរំពឹងថានឹងនៅរឹងមាំ គិតទាំងជាប្រាក់ដុល្លារ និង ជារូបិយវត្ថុប្រទេសជាដៃគូរនានា។

វិស័យសារពើពន្ធមានការរីកចម្រើនខ្លះៗនៅក្នុងឆ្នាំ ២០០៦ ខណៈដែលអនុបាតនៃចំណូលពន្ធចំពោះ GDP បានកើនឡើងបន្តិចពី ៧,៦ ភាគរយក្នុងឆ្នាំ ២០០៥ ដល់កម្រិតប៉ាន់ស្មាន ៨,០ ភាគរយក្នុងឆ្នាំ ២០០៦។ ជាចំណែកមួយនៃ GDP ចំណូលក្រៅពីពន្ធដារនៅទ្រឹងត្រឹម ២,៣ ភាគរយ។ ប៉ុន្តែ គិតជាកំណើនធម្មតាពីមួយឆ្នាំទៅមួយឆ្នាំគឺខ្ពស់ណាស់: ចំណូលពន្ធត្រូវបានប៉ាន់ស្មានថាបានកើនឡើង ២១ ភាគរយក្នុងឆ្នាំ ២០០៦។ ចំណូលក្រៅពីពន្ធត្រូវបានប៉ាន់ស្មានថាបានកើនឡើងប្រហែល ១៦ ភាគរយ ប៉ុន្តែ កំពុងចាប់ផ្តើមពីមូលដ្ឋានដ៏ទាបខ្លាំង។ ចំណាយត្រូវបានប៉ាន់ស្មានថាបានថយចុះបន្តិចមក ១៣,១ ភាគរយនៃGDP នៅក្នុងឆ្នាំ ២០០៦ (ថយចុះពី ១៣,៦ ភាគរយនៃ GDP នៅក្នុងឆ្នាំ ២០០៥) ប៉ុន្តែ ការយកចិត្តទុកដាក់កាន់តែច្រើនឡើងបានបន្តផ្តោតលើវិស័យសង្គមកិច្ចនានា ជាមួយនឹងការកើនឡើងនៃការចំណាយតិចតួច ទោះបីជាចំណាយមូលធនសរុបបានថយចុះយ៉ាងជាក់ស្តែងក្តី។ ក្នុងរយៈពេលមធ្យម តុល្យភាពថវិកាទូទៅ ត្រូវបានរំពឹងថានឹងនៅថេរប្រហែល -៣,៧ ភាគរយនៃ GDP (ដោយមិនរាប់បញ្ចូលជំនួយឥតសំណង)។

ស្រដៀងគ្នានេះដែរ វិស័យហិរញ្ញវត្ថុមានការរីកចម្រើនខ្លះនៅក្នុងឆ្នាំ ២០០៦។ ប្រាក់បញ្ញើសរុប (ប្រាក់បញ្ញើជាប្រាក់រៀល និងរូបិយវត្ថុបរទេស) របស់ធនាគារដែលដំណើរការនៅក្នុងប្រទេសកម្ពុជា បានកើនឡើង ៤៣ ភាគរយ ហើយអនុបាតឱ្យខ្ចីចំពោះប្រាក់បញ្ញើ បានបន្តកើនឡើងដល់ ៦៨ ភាគរយនៅក្នុងឆ្នាំ ២០០៦ (ពី ៦៤ ភាគរយក្នុងឆ្នាំ ២០០៥) ដែលឆ្លុះបញ្ចាំងកំណើនសកម្មភាពអាជីវកម្មក្នុងឆ្នាំ ២០០៦ (ឧទាហរណ៍ ការចុះបញ្ជីអាជីវកម្មបានកើនឡើង ៥០ ភាគរយលើសឆ្នាំ ២០០៥)។ បច្ចុប្បន្ននេះ មានធនាគារចំនួន ២០ កំពុងដំណើរការនៅក្នុងប្រទេសកម្ពុជា ដែលបានកើនឡើងពីធនាគារចំនួន ១៨ នៅចុងឆ្នាំ ២០០៥។ ប៉ុន្តែ ប្រទេសកម្ពុជានៅតែជាប្រទេសសេដ្ឋកិច្ចដុល្លារនីយកម្មដ៏ខ្ពស់ ជាមួយនឹងសាច់ប្រាក់ទូលាយ (M2) ជិត ៧៥ ភាគរយ និងប្រាក់បញ្ញើធនាគារចំនួន ៩៧ ភាគរយធ្វើឡើងជាប្រាក់ដុល្លារអាមេរិក។ អត្រាការប្រាក់ ពាណិជ្ជកម្មនៅតែខ្ពស់ក្នុងកម្រិតប្រហែល ១៦ ភាគរយក្នុងមួយឆ្នាំ។

នៅក្នុងរបៀបវារៈកំណែទម្រង់ស្ថាប័ន កម្មវិធីកំណែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈរបស់រាជរដ្ឋាភិបាលកំពុងបន្តទទួលបាននូវលទ្ធផល ។ ដោយបន្តពីសមិទ្ធផលក្នុងឆ្នាំ ២០០៥ និង ២០០៦ វិធានការកំណែទម្រង់ធំៗវគ្គទីពីរ ត្រូវបានផ្តួចផ្តើមនៅក្នុងខែមករា ឆ្នាំ ២០០៧ ដែលរួមមាន: ការបញ្ជ្រាបដំស៊ីជម្រៅនៃនីតិវិធីប្រតិបត្តិថវិកា ដើម្បីពន្លឿនការបញ្ចេញប្រាក់ជូនស្ថាប័នចំណាយ ការដាក់ឱ្យអនុវត្តនូវការរៀបចំថវិកាផ្អែកលើកម្មវិធីដើម្បីធ្វើឱ្យចំណាយមានសង្គតិភាពកាន់តែប្រសើរឡើងជាមួយនឹងគោលដៅជាអាទិភាពនានានៃផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ និងការអនុម័តនូវប្លង់គណនីដើម្បីកែលម្អការរាយការណ៍អំពីចំណាយ ។ វិធានការទាំងនេះនឹងធ្វើឱ្យប្រសើរឡើងដល់ប្រសិទ្ធិភាពនៃប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ក៏ដូចជា ការកាត់បន្ថយហានិភ័យសារពើពន្ធដែលមាននៅក្នុងប្រព័ន្ធ ដោយកាត់បន្ថយការគម្រាមកំហែងនៃអំពើពុករលួយ ។ ចាប់តាំងពីខែ មករា ឆ្នាំ ២០០៧ អត្រាពន្ធនាំចូលត្រូវបានកាត់បន្ថយដើម្បីឆ្លុះបញ្ចាំងប្រព័ន្ធសុខុដុមនីយកម្មអាស៊ាន និងពិធីសារនៃអង្គការគយពិភពលោក។ នៅក្នុងវិស័យធនាគារ ទោះបីជានៅមានការងារច្រើនដែលត្រូវបំពេញក្តី ក៏កំណែទម្រង់បានបង្ហាញនូវវឌ្ឍនភាពដ៏ច្រើនជាមួយនឹងទំនុកចិត្តជាក់ស្តែងកាន់តែកើនឡើង ដែលឆ្លុះបញ្ចាំងនូវយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យហិរញ្ញវត្ថុ (FSDS) ឆ្នាំ ២០០៦-២០១៥។ យុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យហិរញ្ញវត្ថុដែលគាំទ្រដោយធនាគារអភិវឌ្ឍន៍អាស៊ី នឹងយកចិត្តទុកដាក់លើបញ្ហាប្រឈមគន្លឹះមួយចំនួននៅក្នុងរយៈពេលមធ្យម រួមមាន ការកែលំអប្រតិបត្តិការរបស់គ្រឹះស្ថានហិរញ្ញវត្ថុ ការបង្កើនអន្តរកម្ម និងការពង្រឹងការផ្សារភ្ជាប់រវាងវិស័យធនាគារនិងមីក្រូហិរញ្ញវត្ថុ។

ទោះបីជាមានវឌ្ឍនភាពល្អនៅក្នុងវិស័យជាច្រើនក្តី ក៏ប្រទេសកម្ពុជានៅជួបប្រទះនឹងបញ្ហាប្រឈមដ៏លំបាកចំពោះមុខគោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍។ បញ្ហាប្រឈមទាំងនេះ រួមមានអត្រាភាពក្រីក្រជនបទដ៏ខ្ពស់ការសម្រេចឱ្យបាននូវអត្រាបញ្ចប់ការសិក្សានៅគ្រប់កម្រិតនៃប្រព័ន្ធអប់រំ និងការធ្វើឱ្យប្រសើរឡើងនូវលទ្ធភាពទទួលបានសេវាកម្មសុខាភិបាលប្រកបដោយគុណភាព ជាពិសេស សុខភាពកុមារនិងមាតា។ ប៉ុន្តែអង្កេតប្រជាសាស្ត្រនិងសុខាភិបាលដែលទើបបានផ្សព្វផ្សាយនាពេលថ្មីៗនេះ បង្ហាញវឌ្ឍនភាពខ្លះៗ។ អត្រាមរណភាពទារក (ក្នុងកំណើតរស់ចំនួន ១.០០០) បានថយចុះពី ៩៥ ក្នុងឆ្នាំ ២០០០ មក ៦៦ នៅក្នុងឆ្នាំ ២០០៥ ហើយអត្រាមរណភាពកុមារ (ក្រោមអាយុ ៥ ឆ្នាំ) (ក្នុងកំណើតរស់ចំនួន ១.០០០) បានថយចុះពី ១២៤ ក្នុងឆ្នាំ ២០០០ មក ៨៣ នៅក្នុងឆ្នាំ ២០០៥។ ប្រេវ៉ាឡង់មេរោគអេដស៍ក៏ហាក់ដូចជាបានថយចុះយ៉ាងច្រើនផងដែរ។ សូចនាករដែលអន់ថយគួរឱ្យកត់សម្គាល់ គឺអត្រាមរណភាពមាតា ដែលទំនងជានៅទ្រឹងក្នុងរយៈពេលប្រាំឆ្នាំកន្លងមកនេះ។